ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩២ អនក្រ.បក

ក្រសួងមហាផ្ទៃ
លេខ 5944 ន.រប
ថ្ងៃទី 20 ខែ 11 ឆ្នាំ 2009

ថតចម្លង

# អនុក្រឹត្យ

## ស្តីពី

## ការប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធិអាទិភាពក្នុងការធ្វើចរាចរណ៍

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខនស/រកម/០២០៧/០០៧ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក
- បានឃើញអនុក្រឹត្យលេខ១៦ អនក្រ ចុះថ្ងៃទី២០ ខែ ធ្នូ ឆ្នាំ១៩៩៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងមហាផ្ទៃ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

## ស ម្រេ ច

**មាត្រា១:** អនុក្រឹត្យនេះមានគោលដៅកំណត់ការប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធិអាទិភាពធ្វើចរាចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

មាត្រា២: អនុក្រឹត្យនេះមានគោលបំណង :

- ទប់ស្កាត់ និងលុបបំបាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធិអាទិភាពធ្វើចរាចរណ៍ ។
- កំណត់សិទ្ធិប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធិអាទិភាពធ្វើចរាចរណ៍
- រួមចំណែករក្សាសន្តិសុខ សណ្តាប់ធ្នាប់ និងសុវត្ថិភាពចរាចរណ៍

**មាត្រា៣:** អនុក្រឹត្យនេះមានវិសាលភាព គ្របដណ្តប់លើយានយន្តប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធិអាទិភាពធ្វើចរាចរណ៍ ក្នុងព្រះរាជាណាចក្រកម្ពុជា ។

**មាត្រា៤:** ត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងមានសិទ្ធិអាទិភាពធ្វើចរាចរណ៍ ចំពោះក្បួនយានយន្ត ដូចតទៅ :

**ក.ក្បួនយានយន្តហែរអមថ្នាក់ដឹកនាំជាន់ខ្ពស់ :**

-ក្បួនយានយន្តនគរបាល ឬ កងរាជអាវុធហត្ថ ហែរអមព្រះទីនាំងព្រះមហាវីរក្សត្រ ព្រះវររាជបិតា និងសម្តេចព្រះមហាក្សត្រីយ៍ ព្រះវររាជមាតាជាតិខ្មែរ

-ក្បួនយានយន្តនគរបាល ឬកងរាជអាវុធហត្ថ ហែរអមព្រះទីនាំងព្រះករុណា ព្រះមហាក្សត្រ

-ក្បួនយានយន្តនគរបាល ឬកងរាជអាវុធហត្ថ ហែរអមរថយន្តប្រធានព្រឹទ្ធសភា

-ក្បួនយានយន្តនគរបាល ឬកងរាជអាវុធហត្ថ ហែរអមរថយន្តប្រធានរដ្ឋសភា

-ក្បួនយានយន្តនគរបាល ឬកងរាជអាវុធហត្ថ ហែរអមរថយន្តនាយករដ្ឋមន្ត្រី

**ខ.ក្បួនយានយន្តហែរអមគណៈប្រតិភូផ្លូវការអន្តរជាតិ :**

ក្បួនយានយន្តនគរបាល ឬ កងរាជអាវុធហត្ថ ហែរអមប្រតិភូផ្លូវការអន្តរជាតិ ចាប់ពីថ្នាក់អនុរដ្ឋមន្ត្រីឡើងទៅ និងថ្នាក់ប្រហាក់ប្រហែល តាមសំណើក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ។

**គ.យានយន្តបំពេញភារកិច្ចពិសេស :**

-ក្បួនយានយន្តរបស់កងកំលាំងនគរបាល

-ក្បួនយានយន្តរបស់កងទ័ព និងកងរាជអាវុធហត្ថ

-យានយន្តពន្លត់អគ្គីភ័យ

-យានយន្តសង្គ្រោះរបស់មន្ទីរពេទ្យ

**មាត្រា៥:** ចំពោះយានយន្តដូចបានចែងក្នុង មាត្រា ៤ ចំណុច គ ក្នុងករណីមិនបំពេញភារកិច្ចពិសេស ឬ ភារកិច្ចសង្គ្រោះ គ្មានសិទ្ធិប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរសព្ទពិសេស និងសិទ្ធអាទិភាពក្នុងការធ្វើចរាចរណ៍ឡើយ ។ ក្នុងករណីបំពាន ត្រូវវិនិច្ឆ័យតាមច្បាប់ជាធរមាន។

**មាត្រា៦:** យានយន្តដែលមិនស្ថិតក្នុងមាត្រា ៤ ហាមបំពាក់ភ្លើងសញ្ញាពិសេស និង/ឬ សូរសព្ទពិសេស លើកលែងយានបំរើការងារសាធារណៈ ដូចជា យានលាងសំអាតផ្លូវ យានថែទាំជួសជុលផ្លូវ និងយានដឹកជញ្ជូនពិសេស ដែលបំពាក់ភ្លើងសញ្ញាពិសេស ។ ក្នុងករណីបំពាន ត្រូវឃាត់ទុកយានយន្តធ្វើកំណត់ហេតុបញ្ជូនទៅតុលាការ។

**មាត្រា៧:**. កងកំលាំងនគរបាលចរាចរណ៍ផ្លូវគោក និងកងកំលាំងមានសមត្ថកិច្ចពាក់ពន្ធ័ ត្រូវចាត់វិធានការឱ្យបាន

ឱ្យបានម៉ឺងម៉ាត់ ចំពោះករណើរំលោភក្នុងការប្រើប្រាស់ភ្លើងសញ្ញាពិសេស សូរស័ព្ទពិសេស និងល្បើសសញ្ញាចរាចរណ៍ ។ ទន្ទឹមនោះ ត្រូវយកចិត្តទុកដាក់ក្នុងការរក្សាសណ្តាប់ធ្នាប់ និងការពារសន្តិសុខសុវត្ថិភាពនៅតាមគោលដៅបញ្ចរាចរណ៍ ដែលមានក្បួនយានយន្តដូចមានចែងក្នុងមាត្រា ៤ ឆ្លងកាត់ ។

**មាត្រា៨:** បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា៩:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ និងអភិបាលរាជធានី អភិបាលគ្រប់ខេត្ត ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី....[illegible]....ខែ..[illegible].......ឆ្នាំ២០០៩

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល*:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការនៃរាជរដ្ឋាភិបាល
- ដូចមាត្រា ៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**បានយកសេចក្តីជម្រាបជូន**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីចុះហត្ថលេខា**

**ស ខេង**

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ**